ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០៥៤ សហវ.ប្រក

ថ្ងៃ សុក្រ ១កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០២១

# ប្រកាស
## ស្តីពី
## កម្មវិធីចំណូល-ចំណាយថវិកាថ្នាក់ជាតិប្រចាំត្រីមាសទី ១ ឆ្នាំ ២០២១ របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ ព្រហស្បតិ៍ ០១រោច ខែ បឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២០/០៣៨ ចុះថ្ងៃសុក្រ ១១កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃអង្គារ ១៥កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០២០ ស្តីពីការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១
- បានឃើញអនុក្រឹត្យលេខ ២១៧ អនក្រ.បក ចុះថ្ងៃអង្គារ ១៥កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០២០ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១
- ដោយមានការចាំបាច់ដើម្បីរក្សាតុល្យភាពនៃកិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

# សម្រេច

**ប្រការ១ .-** ចំណូលរបស់ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ដែលខិតខំប្រមូលសម្រាប់ត្រីមាសទី ១ ឆ្នាំ ២០២១ សរុបទឹកប្រាក់ ចំនួន ២៤ ៥០៤ ៦០០ ០០០ រៀល (ម្ភៃបួនប៊ីលានប្រាំរយបួនលានប្រាំមួយរយពាន់រៀលគត់) ឬលើសកម្រិតកំណត់នេះ។ ចំណូលទាំងអស់នេះ ត្រូវបង់ចូលថវិកាថ្នាក់ជាតិឱ្យបានគ្រប់គ្រាន់និងទាន់ពេលវេលា ហើយត្រូវបានបែងចែកតាមជំពូកនៃមាតិកាថវិកានិងតាមខែដូចមានចែងក្នុងតារាងខាងក្រោមនេះ៖

ឯកតា:ពាន់រៀល

| ជំពូក | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២១ | កម្មវិធីចំណូលប្រចាំត្រីមាសទី១ | | | | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | សរុប | ខែមករា | ខែកុម្ភៈ | ខែមីនា | |
| **សរុបរួម** | **82.996.200** | **24.504.600** | **8.168.168** | **8.168.189** | **8.168.243** | |
| ៧៣ | 82.856.200 | 24.470.596 | 8.156.835 | 8.156.856 | 8.156.905 | |
| ៧៤ | 140.000 | 34.004 | 11.333 | 11.333 | 11.338 | |

**ប្រការ២ .-** ចំនួនទឹកប្រាក់ជាអតិបរមា នៃឥណទានរបស់ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ សម្រាប់ចំណាយប្រចាំត្រីមាសទី ១ ឆ្នាំ ២០២១ ត្រូវបានកំណត់ស្មើនឹង ៣១ ៦២៩ ៩០០ ០០០ រៀល (សាមសិបមួយប៊ីលានប្រាំមួយរយម្ភៃប្រាំបួនលានប្រាំបួនរយពាន់រៀលគត់)។ ចំនួនទឹកប្រាក់នៃឥណទាននេះ ត្រូវបានបែងចែកតាមជំពូកនៃមាតិកាថវិកានិងតាមខែដូចមានចែងក្នុងតារាងខាងក្រោមនេះ៖

ឯកតា:ពាន់រៀល

| ជំពូក | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២១ | កម្មវិធីចំណាយប្រចាំត្រីមាសទី១ | | | | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | សរុប | ខែមករា | ខែកុម្ភៈ | ខែមីនា | |
| **សរុបរួម** | **207.331.000** | **31.629.900** | **8.100.325** | **12.489.606** | **11.039.969** | |
| ៦០ | 43.207.000 | 3.024.490 | 864.140 | 864.140 | 1.296.210 | |
| ៦១ | 18.309.000 | 3.295.620 | 549.270 | 915.450 | 1.830.900 | |
| ៦៤ | 90.251.800 | 18.050.380 | 5.415.128 | 6.317.626 | 6.317.626 | |
| ៦២ | 39.330.900 | 3.539.781 | 786.618 | 1.966.545 | 786.618 | |
| ៦៥ | 16.172.300 | 3.719.629 | 485.169 | 2.425.845 | 808.615 | |
| ៦៣ | 60.000 | 0 | 0 | 0 | 0 | |

**ប្រការ៣ .-** អាណត្តិបើកប្រាក់ ដែលចេញដោយអាណាប័កដើមខ្សែលើសពីចំនួនទឹកប្រាក់កម្រិតកំណត់ខាងលើ និងលើសពីការបែងចែកតាមជំពូកនៃថវិកាខាងលើ មិនត្រូវបានទទួលការចុះទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុទេ ហើយក៏មិនត្រូវបានធ្វើការបើកផ្ដល់ដោយបេឡារតនាគារដែរ។

**ប្រការ៤ .-** រាល់ចំណាយចាំបាច់លើសពីកម្រិតកំណត់ឥណទានដូចមានចែងក្នុងប្រការ២ ត្រូវមានការអនុញ្ញាតពីឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៥ .-** អាណាប័កដើមខ្សែក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន**
- អគ្គនាយកដ្ឋានរតនាគារជាតិ
- នាយកដ្ឋានហិរញ្ញកិច្ច
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ